

**ឈ្មោះបេក្ខជន៖** Ry Armstrong (ពួកគេ/ពួកគាត់)

**ឈ្មោះយុទ្ធនាការ៖** Armstrong for All

**គេហទំព័រយុទ្ធនាការ៖** armstrongforall.com

**មុខតំណែងក្រុង៖** ចៅហ្វាយក្រុង Seattle

លេខទូរស័ព្ទយុទ្ធនាការ៖ **+1 206-657-6287**

នៅក្នុងបេះដូងនៃទីក្រុង Seattle ខ្ញុំឈរក្នុងនាមជាអ្នករៀបចំការងារ ដោយដើរតាមគន្លងរបស់គ្រួសារខ្ញុំ។ ខ្ញុំមិនដែលចុះចាញ់នឹងបញ្ហាប្រឈមនោះឡើយ។ ខ្ញុំបានចំណាយពេលជាច្រើនឆ្នាំតស៊ូដើម្បីសិទ្ធិកម្មករ លំនៅឋានមានតម្លៃសមរម្យ និងផ្នែកសិល្បៈ។ ក្នុងនាមជានាយកសហប្រតិបត្តិនៃទីក្រុង Seattle ប្រកបដោយនិរន្តរភាព ខ្ញុំធ្វើការដើម្បីទីក្រុងកាន់តែស្អាត និងយុត្តិធម៌ប្រសើរឡើង ដែលការពារជនងាយរងគ្រោះបំផុតក្នុងចំណោមពួកយើង។ អស់រយៈពេលប្រាំឆ្នាំមកហើយ ខ្ញុំបានធ្វើការជាមួយសហជីព ហើយឥឡូវនេះបម្រើនៅក្រុមប្រឹក្សាជាតិ AFL-CIO នៃ AEA តំណាងឱ្យកម្មករប្រកបដោយភាពច្នៃប្រឌិតចំនួន 50,000 នាក់ ដើម្បីលើកកម្ពស់ឱ្យមានប្រាក់ឈ្នួល សុវត្ថិភាព និងអត្ថប្រយោជន៍សមរម្យ។ ពេលវេលារបស់ខ្ញុំក្នុងនាមជាគណៈកម្មាធិការ LGBTQ ទីក្រុង Seattle និងការតស៊ូមតិជាច្រើនឆ្នាំបានបង្រៀនខ្ញុំពីរបៀបដែលរដ្ឋាភិបាលទីក្រុងធ្វើការ។ ខ្ញុំជឿជាក់ថាការដឹកជញ្ជូនសាធារណៈគួរផ្តល់កាត់បន្ថយតម្លៃ ឬឥតគិតថ្លៃ ដើម្បីជួយដល់ក្រុមគ្រួសារដែលធ្វើការងារ ធ្វើដំណើរជុំវិញទីក្រុងរបស់យើង និងកាត់បន្ថយការបំភាយឧស្ម័នដើម្បីជួយដល់បញ្ហាការប្រែប្រួលអាកាសធាតុ។ ខ្ញុំមានគម្រោងបន្ថែមគ្រែនៅទៅជម្រកចំនួន 1,000 ក្នុងរយៈពេល 100 ថ្ងៃដំបូងរបស់ខ្ញុំ។ ការផ្លាស់ប្តូរច្បាប់ប្រើប្រាស់ដីធ្លីនឹងជួយយើងកសាងមជ្ឈមណ្ឌលថែទាំកុមារ និងធ្វើឱ្យទីក្រុង Seattle កាន់តែរឹងមាំ។ ខ្ញុំនឹងមិនចុះចាញ់នៅឆ្នាំ 2025 ឡើយ ទីក្រុងរបស់យើងត្រៀមខ្លួនជាស្រេចដើម្បីតស៊ូសម្រាប់អនាគតដ៏ល្អប្រសើរមួយ។ ខ្ញុំស្នើសុំការគាំទ្រលោកពីលោកអ្នក។ ពលរដ្ឋគឺជាអាទិភាពចម្បង។ សាមគ្គីភាព!

*បេក្ខជនរូបនេះ គឺកំពុងតែចូលរួមក្នុងកម្មវិធីប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ។*



ឈ្មោះបេក្ខជន៖ **Bruce Harrell**

**ឈ្មោះយុទ្ធនាការ៖** Bruce for Seattle

**គេហទំព័រយុទ្ធនាការ៖** BruceforSeattle.com

**មុខតំណែង៖** អភិបាលក្រុង Seattle

**លេខទូរស័ព្ទយុទ្ធនាការ៖** 206-569-8486

ខ្ញុំមានកិត្តិយសណាស់ដែលបានបម្រើការជាអភិបាលក្រុងរបស់អ្នក! ការធ្វើរជាមួយបុគ្គលិកទីក្រុងដែលមានការប្តេជ្ញាចិត្តរបស់យើង យើងប្តេជ្ញាចិត្តធ្វើឱ្យទីក្រុង Seattle ប្រកបដោយសុវត្ថិភាព ងាយស្រួលរស់នៅ និងជាទីស្វាគមន៍សម្រាប់មនុស្សទាំងអស់គ្នា។

ខ្ញុំមានមោទនភាពណាស់ចំពោះស្នាដៃរបស់យើងរហូតមកដល់ពេលនេះ៖

● ការវិនិយោគលើលំនៅឋានដែលមានតម្លៃសមរម្យ រួមមានលំនៅដ្ឋានឧបត្ថមសម្រាប់បុគ្គលងាយរងគ្រោះបំផុត និងផ្ទះរាប់ពាន់ខ្នងសម្រាប់កម្មករ និងក្រុមគ្រួសារដ៏ច្រើនលើសលប់។

● ការកែលម្អសុវត្ថិភាពសាធារណៈ: រួមមានបុគ្គលិកប៉ូលីសនៃទីក្រុង Seattle ដោយការបង្កើតក្រុមការងារ CARE ផ្តល់នូវការឆ្លើយតបប្រកបដោយការយល់យោគដោយមិនប្រើអាវុធដល់បុគ្គលដែលត្រូវការជំនួយ និងការវិនិយោគលើសុវត្ថិភាពយុវជន និងការទប់ស្កាត់អំពើហិង្សាដោយកាំភ្លើង។

● ធ្វើសកម្មភាពយ៉ាងឆាប់រហ័សលើបញ្ហាអាកាសធាតុដើម្បីធ្វើឱ្យអគារមានប្រសិទ្ធភាពថាមពលប្រសើរឡើង ធ្វើឱ្យការប្រើប្រាស់ផ្លូវឆ្លងកាត់ និងចិញ្ចើមផ្លូវប្រសើរឡើង ពង្រីកស្ថានីយ៍សាកថាមពលរថយន្តដោយថាមពលអគ្គិសនី និងដាំដើមឈើបន្ថែមរាប់ពាន់ដើម។

● ផ្តោតសំខាន់ទៅលើសេវាកម្មមូលដ្ឋាន— ការកែលម្អផ្លូវ ការចេញប័ណ្ណអនុញ្ញាតឲ្យកាន់តែងាយស្រួល និងការគាំទ្រសម្រាប់អាជីវកម្មខ្នាតតូចដ៏រស់រវើករបស់យើង។

តាមរយៈប័ណ្ណទឹកប្រាក់ និងសន្លឹកឆ្នោតរបស់អ្នក យើងនឹងបន្តដំណើរឆ្ពោះទៅមុខទៀត!

● ការពង្រីកលំនៅដ្ឋានដែលមានតម្លៃសមរម្យ— ពីផ្ទះដែលងាយស្រួលសម្រាប់គ្រួសារនៅជិតសាលារៀន ទៅជាអាផាតមិន និងខុនដូនៅក្បែរកន្លែងជិះរថយន្តក្រុង យើងត្រូវតែបង្កើនលទ្ធភាពប្រើប្រាស់ កាត់បន្ថយការចំណាយ និងបង្កើតឱកាសផ្តល់ទ្រព្យសម្បត្តិដល់មនុស្សជំនាន់ក្រោយ។

● វឌ្ឍនភាពលើសុវត្ថិភាព- ការជ្រើសរើសបុគ្គលិក SPD, ការពង្រីកក្រុមការងារ CARE, ការកាត់បន្ថយអំពើហិង្សា និងការដោះស្រាយការប្រើប្រាស់ថ្នាំហ្វៃនតានីល និងសារធាតុញៀន។

● ការពន្លឿនអនាគតរបស់ទីក្រុង Seattle – រថភ្លើងក្រុងពី West Seattle ទៅ Ballard, ការបញ្ចប់ការសាងសង់តាមឆ្នេរទឹក Waterfront និងការគ្រោងឡើងវិញនៃមជ្ឈមណ្ឌល Seattle Center ដោយស្តារទីក្រុងទៅកាន់ភាពអស្ចារ្យនៃ Emerald City ដោយពិតប្រាកដ។

ខ្ញុំស្នើសុំការបន្តគាំទ្ររបស់អ្នក។

*បេក្ខជនរូបនេះ គឺកំពុងតែចូលរួមក្នុងកម្មវិធីប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ។*



ឈ្មោះបេក្ខជន៖ Joe Mallahan

ឈ្មោះយុទ្ធនាការ៖ Mallahan for Mayor

គេហទំព័រយុទ្ធនាការ៖ joemallahanforseattlemayor.com

មុខតំណែងក្នុងទីក្រុង៖ អភិបាលក្រុង Seattle

លេខទូរសព្ទយុទ្ធនាការ៖ 206.229.8149

ខ្ញុំកំពុងឈរឈ្មោះជាអភិបាលក្រុង ព្រោះខ្ញុំជឿថាទីក្រុង Seattle អាចរស់នៅតាមឧត្តមគតិរបស់ខ្លួន។ ដោយរដ្ឋាភិបាលទីក្រុងកាន់តែមានប្រសិទ្ធភាព ទីក្រុង Seattle អាចជាគំរូនៃវឌ្ឍនភាពសម្រាប់ប្រទេសជាតិ ហើយជាកម្លាំងប្រឆាំងនឹងភាពវឹកវរនិងភាពឃោរឃៅរបស់ MAGA។

ក្នុងនាមជាអភិបាលក្រុង ខ្ញុំនឹងធ្វើឱ្យទីក្រុងធ្វើការដើម្បីយើងទាំងអស់គ្នា។ យើងត្រូវតែធ្វើឱ្យសុវត្ថិភាពសាធារណៈប្រសើរឡើងយ៉ាងខ្លាំង ជាមួយនឹងការត្រួតពិនិត្យរបស់ប៉ូលីសពិតប្រាកដ និងការកសាងទំនុកចិត្តសហគមន៍ឡើងវិញ។ ខ្ញុំនឹងចូលរួមការល្បាតរបស់ប៉ូលីស 50 ដងក្នុងឆ្នាំដំបូងរបស់ខ្ញុំដើម្បីអោយខ្ញុំយល់អំពីអ្វីដែលកើតឡើងជាក់ស្តែងក្នុងសហគមន៍របស់យើង។

ខ្ញុំនឹងបន្ថយតម្រូវការរដ្ឋបាល ពន្លឿនការផលិតលំនៅឋាន និងវិនិយោគលើគម្រោងដែលជួយដល់គ្រួសារកម្មករ។ ខ្ញុំនឹងប្រើប្រាស់ឥណទានពន្ធសហព័ន្ធ ដើម្បីសាងសង់ផ្ទះដែលមានតម្លៃសមរម្យ ពង្រីកលទ្ធភាពទទួលបានការព្យាបាលជំងឺផ្លូវចិត្ត និងការញៀន និងមានគ្រែសង្គ្រោះបន្ទាន់ចំនួន 5,000 ក្នុងឆ្នាំដំបូងរបស់ខ្ញុំ–
អ្នកមិនអាចព្យាបាលការញៀននៅពេលដែលមនុស្សរស់រស់នៅតាមដងផ្លូវនោះទេ។

ខ្ញុំបានធ្វើជាភ្នាក់ងារនាំការផ្លាស់ប្តូរក្នុងអំឡុងពេលអាជីពទាំងមូលរបស់ខ្ញុំ–ដែលខ្ញុំធ្វើឱ្យអាជីវកម្មខ្នាតមធ្យមប្រសើរឡើងដោយធ្វើការប្រកៀងស្មាជាមួយបុគ្គលិកជួរមុខ។ នៅ T-Mobile ខ្ញុំបានស្តាប់អ្នកតំណាងផ្នែកសេវាកម្មអតិថិជន ហើយបានផ្តល់សិទ្ធិទទួលបានឥណទាន និងតម្លៃទាបជូនគ្រួសារដែលមានចំណូលទាបរាប់លានគ្រួសារ។ ក្នុងនាមជាអ្នកប្រមូលផ្តុំសហគមន៍ ខ្ញុំបាននាំមនុស្សរួមគ្នាដើម្បីដោះស្រាយបញ្ហាទីក្រុងធំៗ។

យើងអាចដោះស្រាយភាពគ្មានផ្ទះសម្បែងដោយក្តីមេត្តា និងធ្វើឱ្យទីក្រុង Seattle មានសុវត្ថិភាព និងតម្លៃសមរម្យ។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Joe Molloy

**ឈ្មោះយុទ្ធនាការ៖** Joe Molloy for Mayor

**គេហទំព័រយុទ្ធនាការ៖** [joemolloyformayor.com](joemolloyformayor.com)

**មុខតំណែងក្នុងទីក្រុង៖** អភិបាលក្រុង Seattle

**លេខទូរសព្ទយុទ្ធនាការ៖** 206-590-1126

ខ្ញុំឈ្មោះ Joe Molloy — ដែលជាអ្នកតស៊ូមតិផ្នែកលំនៅដ្ឋាន និងពិការភាព អ្នកគិតលើប្រព័ន្ធប្រកបដោយចក្ខុវិស័យ និងជាអ្នកដឹកនាំដែលបង្កើតដោយបទពិសោធន៍រស់នៅលើជួរមុខនៃប្រព័ន្ធដែលខូច។

ខ្ញុំមិនមែនជាអ្នកនយោបាយអាជីពទេ ប៉ុន្តែជាអ្នកបម្រើសាធារណៈដែលជំរុញដោយអារម្មណ៍បន្ទាន់ខ្លាំង។ ខ្ញុំកំពុងឈរឈ្មោះដើម្បីដោះស្រាយ ហើយចុងក្រោយ វិបត្តិនៃភាពគ្មានផ្ទះសម្បែង ដែលបានចាប់ទីក្រុងរបស់យើង។

ខ្ញុំបានផ្លាស់ទៅទីក្រុង Seattle ដោយចេតនា ដោយជឿថាវាជាកន្លែងមួយក្នុងចំណោមកន្លែងមួយចំនួននៅលើពិភពលោក ដែលខ្ញុំអាចបង្ហាញខ្លួនឯងបានពេញលេញ។
ខ្ញុំដឹងថាអ្នកផ្សេងទៀតហៅទីក្រុងនេះថាផ្ទះសម្រាប់ហេតុផលដូចគ្នា។ យើងទាំងអស់គ្នាដឹង — ប្រព័ន្ធរបស់យើងមិនត្រូវគ្នានឹងឧត្តមគតិរបស់យើងទេ។

ប៉ុន្តែពួកគេអាចធ្វើបាន ប្រសិនបើយើងមានឆន្ទៈ និងប្តេជ្ញាចិត្ត។

យុទ្ធនាការរបស់យើងមិនគ្រាន់តែនិយាយអំពីការដោះស្រាយភាពគ្មានផ្ទះសម្បែងប៉ុណ្ណោះទេ វាគឺជាការកសាងទីក្រុងជាមួយនឹងសេវាកម្មសង្គមដែលរួមបញ្ចូល និងទូលំទូលាយ ដែលលទ្ធភាពនៃ *ការ* ក្លាយជាមនុស្សគ្មានផ្ទះសម្បែងលែងមានទៀតហើយ។ ខ្ញុំជឿថាយើងអាចជាទីក្រុងដែលនាំផ្លូវ។ នោះទុកជាគំរូដល់អ្នកដទៃទាំងអស់។

ប្រសិនបើយើងដោះស្រាយភាពគ្មានផ្ទះសម្បែង យើងមិនគ្រាន់តែដោះស្រាយវិបត្តិមួយនោះទេ - យើងដាក់មូលដ្ឋានគ្រឹះសម្រាប់អនាគតដែលមានសុវត្ថិភាព និរន្តរភាព និងពោរពេញដោយលទ្ធភាព។

នោះហើយជាអ្វីដែលខ្ញុំនៅទីនេះដើម្បីបង្កើត - ហើយនោះជាមូលហេតុដែលខ្ញុំស្នើសុំការគាំទ្ររបស់អ្នក។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីប័ណ្ណប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Katie Wilson

**ឈ្មោះយុទ្ធនាការ៖** Wilson សម្រាប់ទីក្រុង Seattle

**គេហទំព័រយុទ្ធនាការ៖** [wilsonforseattle.com](wilsonforseattle.com)

**មុខតំណែងក្រុង៖** ចៅហ្វាយក្រុង Seattle

**លេខទូរសព្ទយុទ្ធនាការ៖** 607- 301 - 1836

ខ្ញុំឈ្មោះ Katie Wilson ហើយខ្ញុំកំពុងឈរឈ្មោះជាចៅហ្វាយក្រុងបន្ទាប់របស់ក្រុង Seattle។

ខ្ញុំបានចំណាយពេល 14 ឆ្នាំចុងក្រោយនៃអាជីពរបស់ខ្ញុំដើម្បីកសាង និងដឹកនាំសម្ព័ន្ធភាពដើម្បីទទួលបានជ័យជំនះសំខាន់ៗសម្រាប់គ្រួសារដែលធ្វើការរួមមាន៖ ប្រាក់ឈ្នួលកម្រិតអប្បបរមាខ្ពស់ជាងមុន ការការពារអ្នកជួលផ្ទះបានរឹងមាំជាងមុន លំនៅឋានដែលមានតម្លៃសមរម្យជាងមុន មធ្យោបាយធ្វើដំណើរសាធារណៈកាន់តែប្រសើរ និងពន្ធលើអ្នកដែលមានលទ្ធភាពបង់ជាជាងមកលើយើងទាំងអស់គ្នា ដែលបង់ច្រើនពេករួចមកហើយ។ ខ្ញុំដឹងពីរបៀបដឹកនាំប្រជាជនឱ្យរួបរួមគ្នាដោយមិនគិតអំពីភាពខុសគ្នា ដើម្បីសម្រេចបាននូវរឿងដ៏អស្ចារ្យ។

ចៅហ្វាយក្រុងបច្ចុប្បន្នជាអ្នកនយោបាយនៅសាលាក្រុងតាំងពីឆ្នាំ 2008។ នាពេលកន្លងមកនេះ តម្លៃជួល ឬទិញផ្ទះនៅក្រុង Seattle កើនឡើងទ្វេដង ហើយមនុស្សកាន់តែច្រើនមិនមានទីជម្រកទៅរស់នៅតាមដងផ្លូវរបស់យើងជាងពេលមុនៗ។

វាមិនចាំបាច់ត្រូវមានរឿងដូច្នេះទេ។ យើងអាចសាងសង់ផ្ទះសម្រាប់យើងទាំងអស់គ្នា។ យើងអាចរស់នៅក្នុងសង្កាត់ដែលគួរឱ្យរស់នៅ និងមានភាពរស់រវើក។ យើងអាចមានអាជីវកម្មតូចៗដែលរីកចម្រើនល្វតលាស់បាន។ យើងអាចមានផ្លូវដែលមានអារម្មណ៍ថាមានសុវត្ថិភាព ព្រោះថាផ្លូវទាំងនោះពិតជាមានសុវត្ថិភាព។ យើងអាចការពារសហគមន៍ជនអន្តោប្រវេសន៍ និងបង្កើតឱកាសសម្រាប់មនុស្សទាំងអស់គ្នា។ យើងអាចធ្វើរឿងនេះបានជាមួយគ្នា។ ប៉ុន្តែទីក្រុង Seattle ត្រូវការអ្នកដឹកនាំថ្មី។

នេះគឺជាទីក្រុងរបស់អ្នក។ ខ្ញុំចង់នាំយកអំណាច និងសំឡេងរបស់អ្នកទៅសាលាក្រុង។ ចូលរួមជាមួយខ្ញុំ ហើយនាំគ្នាសម្រេចកិច្ចការនេះ។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Isaiah Willoughby

**ឈ្មោះយុទ្ធនាការ៖** The People’s Voice

**គេហទំព័រយុទ្ធនាការ៖**

**មុខតំណែង៖** អភិបាលក្រុង Seattle

**លេខទូរសព្ទយុទ្ធនាការ៖** (206) 228-4802

សូមជំរាបសួរ ទីក្រុង Seattle។ ខ្ញុំឈ្មោះ Isaiah Willoughby ហើយខ្ញុំកំពុងឈរឈ្មោះជាអភិបាលក្រុងបន្ទាប់របស់អ្នក។

ខ្ញុំមិនមែនជាអ្នកនយោបាយអាជីពទេ ខ្ញុំជាសមាជិកសហគមន៍ដែលយល់ពីបញ្ហាប្រឈមពិតប្រាកដដែលទីក្រុងរបស់យើងកំពុងជួបប្រទះ។ ខ្ញុំបានធ្វើការផ្នែកលំនៅដ្ឋាន ខ្ញុំបានសិក្សាប្រព័ន្ធវា ហើយខ្ញុំបានឆ្លងកាត់បញ្ហានៃការកើនឡើងនៃតំលៃ និងគោលនយោបាយដែលបែកបាក់។

ខ្ញុំទទួលបានសញ្ញាបត្រផ្នែកអចលនទ្រព្យពីមហាវិទ្យាល័យ North Seattle College ហើយមានបទពិសោធន៍ជាសហគ្រិន និងប្រមូលផ្តុំសហគមន៍។ ខ្ញុំដឹងពីបញ្ហាដោយសារខ្ញុំធ្លាប់ប្រឈមមុខនឹងវាផងដែរ ហើយខ្ញុំដឹងថាដំណោះស្រាយពិតប្រាកដមកបានពីការស្តាប់មនុស្សដែលរងផលប៉ះពាល់ដោយផ្ទាល់។

ក្នុងនាមជាអភិបាលក្រុង ខ្ញុំនឹងផ្តោតលើ៖

- លំនៅឋានដែលពិតជាមានតម្លៃសមរម្យ
- សុវត្ថិភាពសាធារណៈ ដែលបង្កើតទំនុកចិត្តជាមួយសហគមន៍
- សេដ្ឋកិច្ចក្នុងស្រុកដ៏រឹងមាំដែលជួយគ្រួសារធ្វើការ និងអាជីវកម្មខ្នាតតូចឱ្យរីកចម្រើន

យុទ្ធនាការនេះត្រូវបានគេហៅថា <<សម្លេងរបស់មហាជន>> (The People’s Voice) ពីព្រោះខ្ញុំជឿថា ភាពជាអ្នកដឹកនាំគួរតែមានការបើកចំហ តម្លាភាព និងមានមូលដ្ឋានគ្រឹះនៃការបម្រើ មិនមែននយោបាយដូចធម្មតានោះទេ។

យើងរួមគ្នាដើម្បីបង្កើតទីក្រុង Seattle ដែលមនុស្សគ្រប់គ្នាត្រូវបានគេឮ គាំទ្រ និងលើកស្ទួយ។

អរគុណសម្រាប់ការជឿជាក់ និងសំឡេងរបស់អ្នក។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Ann Davison

**ឈ្មោះយុទ្ធនាការ៖** Neighbors for Ann

**គេហទំព័រយុទ្ធនាការ៖** [https://neighborsforann.com/](https://neighborsforann.com/)

**ដំណែងក្នុងទីក្រុង៖** បេក្ខជនមេធាវីក្រុង

**លេខទូរស័ព្ទយុទ្ធនាការ៖** (206) 257 - 2206

ការបម្រើការជាមេធាវីទីក្រុង Seattle តាំងពីឆ្នាំ 2022 គឺជាកិត្តិយសដ៏ធំធេងមួយរបស់ខ្ញុំ ហើយបន្តផ្តល់ជាកម្លាំងដល់ខ្ញុំ ដើម្បីបន្តផ្តោតទៅលើការកែលម្អសុវត្ថិភាពសាធារណៈនៅក្នុងទីក្រុង Seattle។ មិនថាវាគឺជាការផ្តោតរបស់ខ្ញុំទៅលើការដាក់បញ្ចូលឡើងវិញនូវគណនេយ្យភាពទាន់ពេលវេលាទៅក្នុងប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្មរបស់យើង ដោយការធ្វើការជាមួយសមាជិកសភា ឬក្រុមប្រឹក្សាក្រុង ដើម្បីកែលម្អច្បាប់ ឬមុខងាររបស់រដ្ឋាភិបាលរបស់យើងនោះឡើយ ខ្ញុំបានផ្តោតសំខាន់លើរបៀបធ្វើឱ្យប្រព័ន្ធរបស់យើងដំណើរការកាន់តែមានប្រសិទ្ធភាពក្នុងការបំពេញដល់សាធារណជន។
ខ្ញុំបានជំរុញដំណើរការច្បាប់ដើម្បីការពារទីធ្លាសាធារណៈក្នុងទីក្រុងរបស់យើង ជាមួយនឹងការជៀសឆ្ងាយពីតំបន់គ្រឿងញៀន និងតំបន់ពេស្យាចារ រដោយការទប់ស្កាត់សហគ្រាសឧក្រិដ្ឋកម្មដែលឆក់ឱកាសលើជនងាយរងគ្រោះ។ ខ្ញុំគឺជាមន្ត្រីជំនាញមានសម្ថភាពម្នាក់នៃការិយាល័យព្រះរាជអាជ្ញាដែលមានតម្លាភាពទិន្នន័យ និងសេវាកម្មក្នុងសហគមន៍ដែលមិនធ្លាប់មានពីមុនមក ដូច្នេះសាធារណជននឹងទទួលបានព័ត៌មានអំពីការងារ និងមូលដ្ឋានផ្សេងៗរបស់ខ្ញុំសម្រាប់ការសម្រេចចិត្តរបស់ខ្ញុំ។ ជាមួយនឹងគោលបំណងសុវត្ថិភាពសាធារណៈ ខ្ញុំបានប្ដឹងក្រុមហ៊ុនផលិតរថយន្តដែលដាក់រថយន្តដែលមានតម្លៃទាបបំផុតរបស់ពួកគេចូលទៅក្នុងទីផ្សាររបស់យើង ដែលពួកវាមានហានិភ័យខ្ពស់នៃការត្រូវបានគេលួច។ ខ្ញុំបាននាំយក 160M មកកាន់ទីក្រុង Seattle សម្រាប់ការសម្អាតបរិស្ថាននៃស្ទឹង Duwamish ដែលជាការកាត់ក្តីតែមួយដ៏ធំបំផុតនៅក្នុងប្រទេសពីក្រុមហ៊ុនសារធាតុគីមីដ៏ធំមួយ។ ខ្ញុំនៅទីនេះដើម្បីការពារទីក្រុង Seattle និងច្បាប់របស់ទីក្រុងនេះ ហើយនឹងមិនមានភាពនឿយហត់ ឬការបញ្ចប់នោះឡើយ ប្រសិនបើជាប់ឆ្នោតឡើងវិញ។

*បេក្ខជនរូបនេះ កំពុងតែចូលរួមក្នុងកម្មវិធីប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ។*



**ឈ្មោះរបស់បេក្ខជន៖** Erika Evans

**ឈ្មោះរបស់យុទ្ធនាការ៖** បោះឆ្នោតជ្រើសរើស Erika Evans

**គេហទំព័ររបស់យុទ្ធនាការ៖** www.ElectErikaEvans.com

**មុខតំណែងក្រុង៖** មេធាវីក្រុង

**អ៊ីមែលយុទ្ធនាការ៖** info@ElectErikaEvans.com

ខ្ញុំកំពុងតែឈរឈ្មោះធ្វើជាមេធាវីក្រុង Seattle បន្ទាប់ ដោយសារតែខ្ញុំស្រឡាញ់ទីក្រុងនេះ—ហើយខ្ញុំដឹងថាយើងអាចរីកចម្រើនប្រសើរជាងនេះ។ ខ្ញុំកើតនៅក្នុងគ្រួសារមួយដែលមានឫសគល់ស៊ីជម្រៅនៅក្នុងផ្នែកសិទ្ធិពលរដ្ឋ និងសេដ្ឋកិច្ច ហើយខ្ញុំបានរស់នៅឆ្លងកាត់ការលំបាក ដូចមនុស្សជាច្រើននៅក្នុងសហគមន៍របស់យើងបានប្រឈម។ ខ្ញុំបានចំណាយរយៈពេលក្នុងអាជីពរបស់ខ្ញុំ ដើម្បីការពារដល់សិទ្ធិរបស់យើង និងកែលម្អច្បាប់ ដែលធ្វើឱ្យប្រជាជនកាន់តែមានសុវត្ថិភាព។

ខ្ញុំគឺជាបេក្ខជនតែមួយគត់ដែលបានធ្វើការទាំងផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌនៅការិយាល័យមេធាវីទីក្រុង Seattle។ ខ្ញុំដឹងពីរបៀបដែលការិយាល័យនេះដំណើរការ និងរបៀបផ្តល់ការផ្លាស់ប្តូរពិតប្រាកដ។ ក្នុងនាមជាចៅក្រមតុលាការនាពេលបច្ចុប្បន្ន ខ្ញុំមើលឃើញថាគណនេយ្យភាពមានរូបរាងយ៉ាងណា។ ក្នុងនាមជារដ្ឋអាជ្ញាសហព័ន្ធ ខ្ញុំបានកាត់ទោសនិយោជក ដែលបានលួចប្រាក់ខែពីបុគ្គលិក កាត់ទោសបទឧក្រិដ្ឋដោយសារការស្អប់ខ្ពើម និងអ្នកជួញដូរអាវុធនិងថ្នាំហ្វេនតានីលឱ្យទទួលខុសត្រូវ ហើយខ្ញុំបានក្រោកឈរឡើងដើម្បីជនរងគ្រោះនៃអំពើហិង្សា។

សុវត្ថិភាពពិតប្រាកដមិនមែនសំដៅលើត្រឹមតែការចាប់ខ្លួនប៉ុណ្ណោះទេ។ វាសំដៅទៅលើការចាត់អោយមានទំនួលខុសត្រូវដោយមានទឹកចិត្តសន្តោសប្រណី ការការពារការងារ និងការការពារបរិស្ថានយ៉ាងម៉ឺងម៉ាត់ សេរីភាពនៃការបន្តពូជ និងជម្រើសពិតប្រាកដជំនួសដល់ការជាប់ឃុំឃាំង។ នោះហើយជាមូលហេតុដែលខ្ញុំនឹងគាំទ្រដល់តុលាការសហគមន៍ថ្មីមួយដែលផ្តោតលើការស្តារសមត្ថភាពឡើងវិញ មិនមែនការវិវត្តវិលជុំនោះទេ។

នៅពេលដែលសិទ្ធិរបស់យើងស្ថិតនៅក្រោមការវាយប្រហារដោយរដ្ឋបាល Trump យើងត្រូវការមេធាវីទីក្រុងដែលមានបទពិសោធ មិនខ្លាចខ្លាច និងចំណេះដឹងដើម្បីប្រយុទ្ធតស៊ូ ហើយដឹកនាំបានពីថ្ងៃដំបូង។ ខ្ញុំត្រៀមខ្លួនរួចរាល់ហើយ។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Rory O’Sullivan

ឈ្មោះយុទ្ធនាការ៖ **Friends of Rory O’Sullivan**

**គេហទំព័រយុទ្ធនាការ៖** www.electrory.com

**មុខតំណែងក្រុង៖** មេធាវីក្រុង

**លេខទូរស័ព្ទយុទ្ធនាការ៖** 206-356-9852

ទីក្រុង Seattle គួរមានមេធាវីក្រុងដែលផ្តល់អាទិភាពចំពោះការធ្វើឱ្យទីក្រុងរបស់យើងកាន់តែមានសុវត្ថិភាពប្រសើរឡើង។ យើងទាំងអស់គ្នាប្រឆាំងនឹងឧក្រិដ្ឋកម្ម ប៉ុន្តែការប្រឆាំងនឹងឧក្រិដ្ឋកម្មគឺមិនគ្រប់គ្រាន់ឡើយ។ យើងនៅតែរង់ចាំដំណោះស្រាយ។

ការិយាល័យមេធាវីក្រុងបានបិទតុលាការសហគមន៍, មានការឈ្លោះប្រកែកជាមួយចៅក្រមជាប់ឆ្នោត, បានអនុញ្ញាតឱ្យរយៈពេលកាត់ទោសសម្រាប់ការបើកបរស្រវឹងរហូតដល់រយៈពេល 85 ថ្ងៃ, មិនបានធ្វើអ្វីសោះចំពោះសេចក្តីបង្គាប់មិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ហើយបានបរាជ័យក្នុងការបង្កើតទីក្រុងដែលកាន់តែមានសុវត្ថិភាព និងកាន់តែប្រកបដោយសាមគ្គីភាព ដែលពួកគេបានសន្យាថានឹងបង្កើត។

ខ្ញុំបានធ្វើការតស៊ូសម្រាប់កម្មករ ធានាបាននូវសិទ្ធិស្មើភាពដើម្បីចូលដំណើរការក្នុងប្រព័ន្ធច្បាប់របស់យើង និងជាអ្នកសហការដែលមានភាពសកម្មជាមុន។ ខ្ញុំបានត្រៀមខ្លួនជាស្រេចដើម្បីដឹកនាំការិយាល័យមេធាវីក្រុង ដែលជំរុញទៅរកដំណោះស្រាយចំពោះបញ្ហាប្រឈមដែលទីក្រុង Seattle កំពុងជួបប្រទះ។

ខ្ញុំនឹងនាំយកមកតុលាការសហគមន៍វិញ ជាមួយនឹងកំណត់ត្រាដែលកាន់តែប្រសើរ ដើម្បីផ្តល់ឱកាសឱ្យជៀសផុតពីវដ្តនៃឧក្រិដ្ឋកម្ម, ពន្លឿនការកាត់ទោសអំពើហិង្សាក្នុងគ្រួសារ និងការបើកបរស្រវឹង ដូច្នេះយើងនឹងលែងមានការរង់ចាំការប្រព្រឹត្តបទល្មើសឡើងវិញ, ពង្រឹងស្តង់ដាការងាររឹងមាំ ដើម្បីការពារកម្មករពីការធ្វើបាបនៅកន្លែងធ្វើការ និងបង្កើតការិយាល័យមេធាវីក្រុងមានសមត្ថកិច្ច ដោយផ្តោតសំខាន់លើអភិបាលកិច្ចល្អ។

ទទួលបានការគាំទ្រពី៖ គណៈកម្មការធានារ៉ាប់រង Patty Kuderer, សមាជិកព្រឹទ្ធសភារដ្ឋ Rebecca Saldaña, អ្នកតំណាងរដ្ឋ Chipalo Street និង Sharon Tomiko Santos, អតីតសមាជិកក្រុមប្រឹក្សាក្រុង Tammy Morales និង Mike O'Brien, Seattle Dispatchers' Guild និងច្រើនទៀត។

*បេក្ខជនរូបនេះ គឺកំពុងតែចូលរួមក្នុងកម្មវិធីប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Nathan Rouse

**ឈ្មោះយុទ្ធនាការ៖** បោះឆ្នោតឱ្យ Rouse

**គេហទំព័រយុទ្ធនាការ៖** www.voterouse.com

**មុខតំណែងក្រុង៖** មេធាវីក្រុង

**លេខទូរស័ព្ទយុទ្ធនាការ៖** 206-593-2203

ខ្ញុំគឺ **Nathan Rouse** ជា**អ្នកការពារសាធារណៈ អ្នកតស៊ូមតិផ្នែកច្បាប់ និងជាឪពុក** ដែលឈរឈ្មោះជា**មេធាវីរបស់ទីក្រុង** Seattle អាណត្តិក្រោយនេះ។ ខ្ញុំបានចំណាយពេលក្នុងអាជីពរបស់ខ្ញុំជាអ្នកការពារក្តីសាធារណៈដើម្បីការពារមនុស្សដែលទទួលរងបរាជ័យដោយបញ្ហាប្រព័ន្ធ ព្រមទាំងតស៊ូដើម្បីភាពយុត្តិធម៌ ការទទួលខុសត្រូវ និងឱកាសទីពីរ។

ខ្ញុំឈរឈ្មោះព្រោះខ្ញុំយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះទីក្រុងនេះ ហើយជឿថាយើងត្រូវការប្រព័ន្ធយុត្តិធម៌ដែលអនុវត្តទៅលើ**មនុស្សគ្រប់គ្នា — មិនមែនត្រឹមតែអ្នកមានអំណាចនោះទេ** ។ យើងត្រូវការ**ដំណោះស្រាយសុវត្ថិភាពសាធារណៈពិតប្រាកដ** ដែលដោះស្រាយឧក្រិដ្ឋកម្មមជ្ឈិមធ្ងន់ធ្ងរ ខណៈពេលដែលផ្តល់ជូននូវការស្តារនីតិសម្បទា និងការគាំទ្រដ៏មានអត្ថន័យសម្រាប់មនុស្សដែលវិលចូលសហគមន៍របស់យើងឡើងវិញ។ យើងត្រូវ**ការពារកម្មករ និងអ្នកជួល បង្កើតមូលនិធិសំណងដ៏រឹងមាំជាងមុនសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម** និងក្រោកឈរឡើងចំពោះ**គុណតម្លៃរីកចម្រើននៃទីក្រុង Seattle** ជាពិសេសនៅពេលដែលពួកគេរងការវាយប្រហារពីរដ្ឋបាលលោក Trump ។ យើងមិនអាចពឹងផ្អែកលើមេធាវីក្រុងសាធារណរដ្ឋរបស់យើងជាខ្នងបង្អែកទេ។

ជារៀងរាល់ថ្ងៃខ្ញុំឃើញដោយផ្ទាល់ពីរបៀបដែលវិធីសាស្រ្តរបស់យើងចំពោះយុត្តិធម៌មិនមានប្រសិទ្ធភាពក្នុងពេលបច្ចុប្បន្ននេះ។ ជាញឹកញយពេក យើងបង្ខិលមនុស្សតាមប្រព័ន្ធដោយមិនបញ្ឈាក់ពីមូលហេតុនៃឧក្រិដ្ឋកម្ម ឬកំណត់ពួកគេឱ្យទទួលបានជោគជ័យនៅពេលពួកគេចាកចេញ ដើម្បីកុំឱ្យពួកគេប្រព្រឹត្តម្តងទៀត។ ខ្ញុំនឹងផ្តោតទៅលើ**គោលនយោបាយដែលជំរុញដោយទិន្នន័យ** ដែលពិតជាធ្វើឱ្យសុវត្ថិភាពសាធារណៈប្រសើរឡើង ខណៈពេលដែលធានានូវការទទួលខុសត្រូវប្រកបដោយអត្ថន័យ។

ខ្ញុំឈរឈ្មោះដើម្បីបង្កើត**ទីក្រុង Seattle ដែលមានសុវត្ថិភាព និងយុត្តិធម៌ជាងមុន** ហើយខ្ញុំសង្ឃឹមថាអ្នកនឹងចូលរួមជាមួយខ្ញុំ។

*បេក្ខជនរូបនេះ គឺកំពុងតែចូលរួមក្នុងកម្មវិធីប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Eddie Lin

**ឈ្មោះយុទ្ធនាការ៖** Eddie សម្រាប់ទីក្រុង Seattle

**គេហទំព័រយុទ្ធនាការ៖** https://www.linforseattle.com/

**មុខតំណែងក្រុង៖** តំណែងក្រុមប្រឹក្សាក្រុង 2

**លេខទូរស័ព្ទយុទ្ធនាការ៖** 206-734-7412

ក្នុងនាមជាជំនួយការមេធាវីក្រុងសម្រាប់ការិយាល័យលំនៅឋាន លោក Eddie បានធ្វើការអស់ជាច្រើនឆ្នាំដើម្បីជួយផ្តល់ថវិការាប់ពាន់យូនីតនៃលំនៅឋានដែលមានតម្លៃសមរម្យ។ លោកជឿថា ការកាត់បន្ថយថ្លៃផ្ទះជួលដែលមានតម្លៃដ៏ខ្ពស់គួរតែជាអាទិភាពកំពូល។ Eddie នឹងធ្វើការដោយមិនចេះនឿយហត់ដើម្បីដោះស្រាយកេរ្តិ៍ដំណែលនៃការកំណត់តំបន់ដែលមិនរាប់បញ្ចូល ការរើសអើងដោយវណ្ណៈ និងការខ្វះខាតជាប្រព័ន្ធនៃការវិនិយោគដែលបានដាក់បន្ទុកលើទីក្រុងរបស់យើងអស់ជាច្រើនទសវត្សរ៍ ជាពិសេសតំបន់ South End ។

Eddie គឺជាកូនប្រុសរបស់ជនអន្តោប្រវេសន៍ពីតៃវ៉ាន់ និងប្រឈមមុខនឹងការរើសអើងខណៈដែលគាត់បានធំធាត់ឡើងនៅរដ្ឋ North Carolina ។ គាត់បានពឹងផ្អែកលើអាហារូបករណ៍ ជំនួយហិរញ្ញវត្ថុ និងបានធ្វើការជាច្រើនមុខងារ ដើម្បីជួយបង់ថ្លៃមហាវិទ្យាល័យ។ គាត់ជាជាងលាបថ្នាំផ្ទះ អ្នកអនាម័យនៅព្រះវិហារក្នុងតំបន់ និងជាអ្នកនាំសារតាមកង់។ កាសែត The Stranger បានលើកឡើងបែបនេះថា "វិបត្តិលទ្ធភាពទិញទំនិញរបស់ទីក្រុង Seattle មិនមែនជារឿងថ្មីសម្រាប់ Eddie នោះទេ គាត់ជួបប្រទះអស់ហើយ" ។

Eddie ឈរឈ្មោះដោយសារតែគាត់មានការខកចិត្តដោយសារការខ្វះភាពរហ័សរហួនក្នុងការដោះស្រាយបញ្ហាប្រឈមដ៏លំបាកបំផុតរបស់ទីក្រុង Seattle ។ មិនថាវាជាបញ្ហាសុវត្ថិភាពសាធារណៈ លទ្ធភាពក្នុងការចំណាយ ភាពគ្មានផ្ទះសម្បែង ឬសាលារដ្ឋដែលជួបការលំបាកនោះទេ គាត់ត្រៀមខ្លួនរួចជាស្រេចដើម្បីចូលប្រឡូក និងធ្វើឱ្យមានការរីកចម្រើនជាក់ស្តែង។

Eddie ជឿជាក់ថា ទីក្រុង Seattle គួរតែជាកន្លែងសម្រាប់មនុស្សគ្រប់ៗគ្នា ហើយនោះហើយជាមូលហេតុដែលគាត់គាំទ្រការយកពន្ធលើសាជីវកម្មអ្នកមាន និងអ្នកមានបំផុត ដើម្បីផ្តល់មូលនិធិដល់សេវាកម្មសំខាន់ៗដែលយើងពឹងផ្អែកទៅលើ។

*បេក្ខជនរូបនេះ គឺកំពុងតែចូលរួមក្នុងកម្មវិធីប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Adonis Ducksworth

**ឈ្មោះយុទ្ធនាការ៖** Adonis សម្រាប់ទីក្រុង Seattle

**គេហទំព័រយុទ្ធនាការ៖** [AdonisForSeattle.com](AdonisForSeattle.com)

**មុខតំណែងក្រុង៖** តំណែងក្រុមប្រឹក្សាក្រុង 2

**លេខទូរសព្ទយុទ្ធនាការ៖** 206-495-5597

ខ្ញុំត្រូវបានចិញ្ចឹមដោយម្តាយតែម្នាក់ឯងនៅផ្ទះជួលបីខ្នងនៅ Beacon Hill។ ខ្ញុំមានអនុស្សាវរីយល្អៗជាច្រើនពីការលេងជាមួយមិត្តភ័ក្តិនៅទូទាំងសង្កាត់។ លំនៅដ្ឋានតម្លៃសមរម្យ និងសេវាកម្មនានានៅជិតសាលារៀនមានសារៈសំខាន់ណាស់ចំពោះស្ថិរភាពរបស់យើង។

សព្វថ្ងៃនេះប្រជាពលរដ្ឋព្រួយបារម្ភពីអំពើហិង្សាដោយប្រើកាំភ្លើង មិនមានលទ្ធភាពទិញផ្ទះ ចាកចេញពីផ្ទះដោយសារផ្ទះថ្លៃពេក និងខ្វះឱកាសសម្រាប់ក្មេងៗ។

អស់រយៈពេល 10 ឆ្នាំចុងក្រោយនេះ ខ្ញុំបានធ្វើការជាអ្នកចុះផ្សព្វផ្សាយ អ្នកចូលរួម និងអ្នកជំនាញខាងគោលនយោបាយនៅទីក្រុង Seattle។ នៅទូទាំងទីក្រុង ខ្ញុំមានប្រវត្តិជាអ្នកប្រមូលមនុស្សមកជុំគ្នាដើម្បីធ្វើកិច្ចការនានា។

ខ្ញុំកំពុងឈរឈ្មោះព្រោះខ្ញុំដឹងថាយើងអាចធ្វើបានប្រសើរជាងនេះសម្រាប់សហគមន៍របស់យើង។

ជាមួយនឹងការបោះឆ្នោតរបស់អ្នក ខ្ញុំនឹងបង្កើតឱ្យបានលទ្ធផលដែលយើងសមនឹងទទួលបាន៖

- ជម្រើសលំនៅឋានកាន់តែប្រសើរសម្រាប់អ្នកដែលចង់រស់នៅក្នុងតំបន់ Southend។ ជម្រើសកាន់តែច្រើនសម្រាប់អ្នកដែលចង់ស្នាក់នៅក្នុងផ្ទះ និងសង្កាត់របស់ពួកគេ។
- មន្ត្រីប៉ូលិសដែលមានទំនួលខុសត្រូវជាងមុន បន្ថែមអ្នកឆ្លើយតបនៃក្រុម CARE និងការវិនិយោគលើអន្តរាគមន៍ ដែលកាត់បន្ថយអំពើហិង្សាដោយកាំភ្លើង និងការពារកុមារ និងអាជីវកម្មខ្នាតតូច។
- ខ្ញុំនឹងធ្វើការដើម្បីបន្ថយល្បឿនរថយន្តនៅ Rainier និង MLK ធ្វើឱ្យការធ្វើដំណើរតាមមធ្យោបាយដឹកជញ្ជូនសាធារណៈមានសុវត្ថិភាព និងប្រកបដោយទំនុកចិត្ត ហើយផ្តល់ឱ្យអ្នកប្រើប្រាស់ទាំងអស់នូវជម្រើសប្រកបដោយសុវត្ថិភាព ដែលអាចទាយទុកជាមុនបាន និងមានប្រសិទ្ធភាពជាងមុន ដោយធ្វើឡើងពីជោគជ័យនៃច្បាប់ដឹកជញ្ជូន។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យ។*



ឈ្មោះបេក្ខជន៖ Jeanie Chunn

ឈ្មោះយុទ្ធនាការ៖ Vote for Jeanie

គេហទំព័រយុទ្ធនាការ៖ votejeanie.com

មុខតំណែងក្រុង៖ តំណែងក្រុមប្រឹក្សាក្រុង 2

លេខទូរសព្ទយុទ្ធនាការ៖ 206-255-4562

ក្នុងគ្រាដ៏សំខាន់នេះ ទីក្រុង Seattle ត្រូវការសមាជិកក្រុមប្រឹក្សាដែលស្តាប់ដោយយកចិត្តទុកដាក់ — ជាមនុស្សម្នាក់ដែលបានចាក់ឫសគល់នៅក្នុងសហគមន៍ ដែលមិនត្រូវបានរងឥទ្ធិពលដោយក្រុមពិសេសណាមួយ និងត្រៀមខ្លួនរួចជាស្រេចដើម្បីប្រយុទ្ធប្រឆាំងដើម្បីការផ្លាស់ប្តូរដ៏ខ្លាំងក្លា ប្រកបដោយវឌ្ឍនភាព។ ខ្ញុំឈរឈ្មោះជាសម្លេងនោះ។

ទីក្រុងរបស់យើងប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរ៖ រចនាសម្ព័ន្ធពន្ធដារថយក្រោយដែលផ្តល់ផលប្រយោជន៍ដល់អ្នកមាន នាយកដ្ឋានប៉ូលីសខ្វះការទទួលខុសត្រូវ និងរដ្ឋបាលដែលដាក់ទោសភាពក្រីក្រជាជាងការដោះស្រាយបញ្ហាឫសគល់របស់វា។ យើងត្រូវការភាពជាអ្នកដឹកនាំដែលមិនត្រឹមតែនិយាយពីគុណតម្លៃប៉ុណ្ណោះទេ ប៉ុន្តែរស់នៅស្របនឹងពួកវា។

ក្នុងនាមជាអ្នកតស៊ូមតិយូរមកហើយ ខ្ញុំបានជួយអនុម័តគោលនយោបាយផ្លាស់ប្តូរ៖ JumpStart Seattle ច្បាប់ Pay Up ការកំណត់ថ្លៃដឹកជញ្ជូន ច្បាប់អនុញ្ញាតឱ្យទទួលទានអាហារក្រៅផ្ទះដោយឥតគិតថ្លៃ និងធានាបាននូវការផ្តល់ជំនួយពីសហព័ន្ធចំនួន $28.6 ពាន់លានដុល្លារសម្រាប់ភោជនីយដ្ឋានឯករាជ្យទូទាំងប្រទេស។ ខ្ញុំចេះធ្វើការងារហ្នឹង ហើយខ្ញុំត្រៀមធ្វើសម្រាប់ស្រុកយើងរាល់ថ្ងៃ។

ខ្ញុំប្តេជ្ញាចិត្តឱ្យមានលំនៅដ្ឋានដែលមានតម្លៃសមរម្យ ដែលផ្តោតលើប្រជាជនជាជាងលើប្រាក់ចំណេញ សុវត្ថិភាពសាធារណៈដែលចេញមកពីដំណោះស្រាយបំផុសពីសហគមន៍ និងសេដ្ឋកិច្ចក្នុងតំបន់ដែលរីកចម្រើន ដែលទទួលជោគជ័យបានដោយអាជីវកម្មខ្នាតតូច និងកម្មករ។

រួមគ្នាយើងអាចកសាងទីក្រុងមួយដែលមានតម្លៃសមរម្យ ដែលមានទំនួលខុសត្រូវ និង ដែលស្វាគមន៍គ្រប់ៗគ្នា។ ចូរផ្លាស់ប្តូរអំណាចចេញពីផលប្រយោជន៍របស់ក្រុមហ៊ុន ហើយផ្តោះមកមនុស្សដែលរស់នៅ Seattle វិញ។ ខ្ញុំសុំអ្នកបោះឆ្នោតឱ្យខ្ញុំ ដើម្បីជួយបង្កើតទីក្រុងមួយដែលមនុស្សគ្រប់គ្នាសំខាន់ ហើយគ្រប់គ្នារីកចម្រើន។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យ។*



ឈ្មោះបេក្ខជន៖ Jamie Fackler

ឈ្មោះយុទ្ធនាការ៖ Jamie for Seattle

គេហទំព័រយុទ្ធនាការ៖ [jamieforseattle.com](http://jamieforseattle.com)

មុខតំណែងក្រុង៖ តំណែងក្រុមប្រឹក្សាក្រុង 2

លេខទូរសព្ទយុទ្ធនាការ៖ 206-963-3211

ទីក្រុង Seattle គឺជាទីក្រុងមួយក្នុងចំណោមទីក្រុងដែលមានជាងគេបំផុតនៅលើភពផែនដី ប៉ុន្តែវាមិនមានអារម្មណ៍បែបនេះទេ។ យើងមានមហាសេដ្ឋីគេចការបង់ពន្ធ ខណៈពេលដែលគ្រួសារដែលគ្មានសូម្បីតែរបស់របរមូលដ្ឋាន។ នេះមិនមែនជាវិបត្តិធនធានទេ វាជាវិបត្តិអាទិភាព។

គ្រួសារអ្នកធ្វើការធ្លាប់ទិញផ្ទះ ហើយរីកចម្រើននៅទីនេះ។ យើងមិនចាំបាច់ទទួលយកស្ថានភាពថ្មីនោះទេ។ ខ្ញុំកំពុងឈរឈ្មោះដើម្បីបង្កើតទីក្រុង Seattle ដែលគ្រប់គ្នាមានផ្ទះ ក្មេងគ្រប់រូបមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការដើរទៅសាលារៀន និងជាកន្លែងដែលសហគមន៍របស់យើងពោរពេញដោយក្តីសង្ឃឹម។

ខ្ញុំគាំទ្រកម្មវិធីសាងសង់ផ្ទះសម្រាប់សង្គម (Social Housing) ក្នុងការផ្តល់នូវលំនៅដ្ឋានដែលមានគុណភាពខ្ពស់ ដែលសាងសង់ដោយសហជីព នឹងជាប្រយោជន៍សាធារណៈ។ ខ្ញុំនឹងពង្រីកឱកាសសម្រាប់លំនៅដ្ឋានដែលមានតម្លៃសមរម្យជាអចិន្ត្រៃយ៍ ការពារសិទ្ធិអ្នកជួល និងកសាងសមត្ថភាពជម្រក។ ការិយាល័យរបស់ខ្ញុំនឹងពង្រីកក្រុមថែទាំ និងអង្គការគាំទ្រដែលធ្វើការដើម្បីដោះស្រាយវិបត្តិគ្រឿងញៀន និងសុខភាពផ្លូវចិត្តរបស់យើង។ យើងនឹងបដិសេធមិនទទួលយកកិច្ចសន្យារបស់ប៉ូលីសដោយគ្មានវិធានគណនេយ្យភាព កម្មវិធីបង្វែរមូលនិធិ និងស្តារអារម្មណ៍សុវត្ថិភាពនៅក្នុងទីក្រុងរបស់យើង។ ខ្ញុំមិនមែនជាអ្នកនយោបាយអាជីពទេ ប៉ុន្តែទីក្រុងរបស់យើងសមនឹងមានមនុស្សធម្មតាធ្វើការក្នុងសាលាក្រុង។

អ្នកគាំទ្រ៖ King County King County Democrats, 37th District Democrats, County Councilmember Teresa Mosqueda, Tammy Morales, Larry Gossett, MLK Labor, PROTEC17, ILWU19, ATU587, SUP, IAM751, AFT Washington, UAW4121។ ខ្ញុំនឹងមានកិត្តិយសប្រសិនបើអ្នកគាំទ្រខ្ញុំផងដែរ។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យ។*



ឈ្មោះបេក្ខជន៖ Jesse A. James

ឈ្មោះយុទ្ធនាការ៖ Jesse A. James for Seattle

គេហទំព័រយុទ្ធនាការ៖ [jesseajames.com](jesseajames.com)

មុខតំណែងក្នុងទីក្រុង៖ តំណែងក្រុមប្រឹក្សាក្រុង

លេខទូរសព្ទយុទ្ធនាការ៖ (206) 657-7062

ក្នុងនាមជាតន្ត្រីករ/អ្នកនិពន្ធជំនាន់សហសវត្សរ៍ ដែលដឹងពីការតស៊ូធ្វើការ និងជួលផ្ទះនៅ Seattle ដោយផ្ទាល់ អាទិភាពចម្បងរបស់ខ្ញុំក្នុងនាមជាសមាជិកក្រុមប្រឹក្សា គឺធ្វើឱ្យទីក្រុង Seattle មានសុវត្ថិភាព និងតម្លៃសមរម្យសម្រាប់មនុស្សគ្រប់គ្នា។

នៅឆ្នាំ 2022 ខ្ញុំបានឈរឈ្មោះសម្រាប់សភានៅលើផទិកាមួយដែលផ្តោតលើកំណែទម្រង់ពន្ធ និងការការពារសិទ្ធិបន្តពូជ។ ខ្ញុំបានចូលរួមជាមួយគណបក្សថ្មីដែលហៅថា Cascade Party នៅឆ្នាំ 2024 ហើយត្រូវបានជ្រើសរើសជាក្រុមប្រឹក្សាភិបាលរបស់គណបក្ស បន្ទាប់ពីការខិតខំប្រឹងប្រែងដ៏ជោគជ័យមួយ ក្នុងបន្ថែមសេរីភាពនៃការនិយាយ និងការថែទាំសុខភាពជាសកលទៅកាន់ផទិការបស់ពួកគេ។

ខ្ញុំជឿថាមនោគមវិជ្ជាគួរតែស្ថិតនៅពីក្រោយការអនុវត្តភាពជាក់ស្តែង និងសហគមន៍ នៅពេលនិយាយអំពីរដ្ឋាភិបាលមូលដ្ឋាន។ នេះគឺជាកន្លែងដែលការផ្លាស់ប្តូរពិតប្រាកដកើតឡើង។

គោលនយោបាយសហព័ន្ធមានភាពច្របូកច្របល់ ហើយយើងត្រូវការស្ថិរភាពនៅក្នុងរដ្ឋាភិបាលមូលដ្ឋាន។ Seattle មានការរីកវិវឌ្ឍក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ ដោយមានសុវត្ថិភាពសាធារណៈ និងលំនៅឋាន ទន្ទឹមនឹងការរក្សាទីក្រុងរបស់យើងឱ្យមានភាពទាក់ទាញសម្រាប់អាជីវកម្ម។ យើងអាចស្វែងរកចំណុចល្អដោយផ្តល់នូវកម្មវិធីសង្គមប្រកបដោយក្តីមេត្តា ខណៈពេលដែលយើងផ្តល់ជំនួយដល់ម្ចាស់អាជីវកម្មខ្នាតតូចផងដែរ។

ខ្ញុំគាំទ្រការបន្តពង្រីកផ្លូវរថភ្លើងធុនស្រាល។ ខ្ញុំជាអ្នកតស៊ូមតិសម្រាប់ការលុបចោលពន្ធដាលើភេសជ្ជៈដែលមានជាតិផ្អែម Sugar Tax។ គោលនយោបាយទាំងនេះស្របនឹងគោលដៅរបស់ខ្ញុំ ពោលគឺនាំមកនូវការទទួលខុសត្រូវ និងតុល្យភាពដល់ក្រុមប្រឹក្សា ហើយខ្ញុំនៅទីនេះដើម្បីខិតខំប្រឹងប្រែងធ្វើការងារ!

បង្ហាញការគាំទ្រពី Krist Novoselic និងច្រើនទៀត។

*បេក្ខជនរូបនេះមិនបានចូលរួមក្នុងកម្មវិធីបណ្តុប្រជាធិបតេយ្យទេ។*



ឈ្មោះបេក្ខជន៖ Rachael Savage

ឈ្មោះយុទ្ធនាការ៖ Friends of Rachael Savage – City Council

គេហទំព័រយុទ្ធនាការ៖ http://www.savageforseattle.com

មុខតំណែងក្រុង៖ តំណែងក្រុមប្រឹក្សាក្រុង ៨

លេខទូរសព្ទយុទ្ធនាការ៖ (206) 657-7062

ក្នុងនាមជាម្ចាស់អាជីវកម្មនៅ Seattle ខ្ញុំត្រូវរស់នៅជាមួយនឹងផលវិបាកដែលបណ្តាលមកពីអ្នកនយោបាយរុះរើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់យើង ដែលអនុញ្ញាតឱ្យឧក្រិដ្ឋកម្ម ការញៀន និងជំងឺផ្លូវចិត្តបណ្តាលឱ្យមានសេចក្តីស្លាប់ ការបំផ្លាញអាជីវកម្មរបស់យើង និងទីប្រជុំជនដ៏ស្រស់ស្អាត និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋគ្រប់រូប។ ក្នុងនាមជាអ្នកមានទីលំនៅទីនេះ ខ្ញុំត្រូវតស៊ូជាមួយនឹងការកើនឡើងនៃថ្លៃជួលផ្ទះដែលមិនធ្លាប់មាន ហើយបានជួបប្រទះនឹងការឡើងថ្លៃផ្ទះពេក។ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាក្រុងរបស់អ្នក បេសកកម្មរបស់ខ្ញុំគឺបម្រើអ្នកដោយធ្វើធរមាននៃគោលនយោបាយដើម្បីបិទគម្លាតនៃប្រាក់ឈ្នួលធៀបនឹងថ្លៃជួលផ្ទះ កសាងនាយកដ្ឋានប៉ូលីសរបស់យើងឡើងវិញ កាន់កាប់គុកនៃទីក្រុងរបស់យើង អនុញ្ញាតឱ្យមានការចាប់ខ្លួន និងការកាត់ទោសដាក់ពន្ធនាគារ និងសាងសង់មជ្ឈមណ្ឌលព្យាបាលដែលអាចស្នាក់នៅរយៈពេលវែងដើម្បីដោះស្រាយការរីករាលដាលនៃគ្រឿងញៀន និងជំងឺផ្លូវចិត្ត។

យើងអាចធ្វើបានល្អជាងនេះ។ ប្រជាពលរដ្ឋគ្រប់រូបមានក្តីប្រាថ្នាដូចគ្នា គឺចង់បានយុត្តិធម៌តាមច្បាប់ និងរស់នៅក្នុងសង្គមដែលមានសន្តិភាព ស្ថិរភាព វិបុលភាព។ សុវត្ថិភាពនឹងនាំមកនូវអាជីវកម្មនិងភាពចម្រុងចម្រើនត្រឡប់មកកាន់ទីក្រុងរបស់យើង។ យើងអាចធ្វើនេះបានជាមួយគ្នា។ តាមរយៈសន្លឹកឆ្នោតរបស់អ្នក ខ្ញុំនឹងតំណាងឱ្យសំឡេងដែលមិនធ្លាប់ឮ សំឡេងសុភវិនិច្ឆ័យ សំឡេងរួបរួមប្រឆាំងនឹងស្ថានភាពដែលបានធ្វើឱ្យយើងបរាជ័យមកយូរពេកហើយ។ បណ្ណប្រជាធិបតេយ្យជួយផ្តល់មូលនិធិដល់អ្នកខាងក្រៅ។ គាំទ្រយុទ្ធនាការរបស់ខ្ញុំជាមួយនឹងបណ្ណប្រជាធិបតេយ្យរបស់អ្នកនៅថ្ងៃនេះ។

បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យ។



ឈ្មោះបេក្ខជន៖ Ray A. Rogers

ឈ្មោះយុទ្ធនាការ៖ Ray A. Rogers (សម្រាប់ក្រុមប្រឹក្សាក្រុង Seattle មុខតំណែងលេខ 8)

គេហទំព័រយុទ្ធនាការ៖ www.RayRogersForSeattle.com

មុខតំណែង៖ 8

លេខទូរសព្ទយុទ្ធនាការ៖ 206-641-0859

ខ្ញុំដឹងថាមានអ្វីកើតឡើងនៅពេលដែលរដ្ឋាភិបាលបរាជ័យ ដោយសារខ្ញុំធ្លាប់ឆ្លងកាត់វាមកហើយ។ ខ្ញុំធំឡើងនៅភាគអាគ្នេយ៍នៃទីក្រុង Seattle នៅពេលដែលក្មេងៗច្រើនពេក រួមទាំងខ្ញុំត្រូវបានទាញចូលទៅក្នុងអំពើហិង្សា និងការញៀន។ ខ្ញុំបានប្រឈមមុខនឹងភាពគ្មានផ្ទះសម្បែង ការប្រើប្រាស់គ្រឿងញៀន និងការជាប់ឃុំឃាំងជាច្រើនឆ្នាំ។ ជីវិតរបស់ខ្ញុំអាចត្រូវបានបញ្ចប់នៅពេលនោះ។ ប៉ុន្តែវាមិនបានកើតឡើងដូចនោះទេ ពីព្រោះអ្នកដឹកនាំសហគមន៍ម្នាក់បានចំណាយពេលវេលារបស់គាត់ក្នុងការជឿជាក់លើខ្ញុំ នៅពេលដែលខ្ញុំគ្មាននរណាម្នាក់ផ្សេងទៀត។ ខ្ញុំបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំ។ ហើយអស់រយៈពេល 20 ឆ្នាំកន្លងមកនេះ ខ្ញុំបានធ្វើការដើម្បីជួយអ្នកដទៃអោយធ្វើដូចគ្នា។

ឥឡូវនេះ ខ្ញុំកំពុងឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាក្រុង Seattle ព្រោះទីក្រុងរបស់យើងស្ថិតនៅផ្លូវបំបែកមួយ។ ខ្ញុំមានបទពិសោធពិតប្រាកដក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម និងការញៀន។ ខ្ញុំជាស្ថាបនិកនៃកម្មវិធី Circle of Love Outreach ដែលជាកម្មវិធីមូលដ្ឋានដែលគាំទ្រមនុស្សប្រឈមមុខនឹងការញៀន អំពើហិង្សា និងភាពគ្មានផ្ទះសម្បែង។

ក្រុមប្រឹក្សាមួយចំនួនចង់ឱ្យយើងត្រឡប់ទៅរកភាពមិនដំណើរការប្រក្រតី ការបែកបាក់ និងការបដិសេធការពិតដែលបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងខ្លាំង។ សូមកុំឱ្យវាកើតឡើង។ ខ្ញុំនឹងធ្វើការដើម្បីជួយមនុស្សរើចេញពីតង់ និងចូលទៅនៅក្នុងផ្ទះមួយដោយក្តីមេត្តា និងភាពបន្ទាន់។ ខ្ញុំនឹងដាក់ទុនលើកម្មវិធីយុវជន ការការពារពីអំពើហិង្សា ជំនួយសុខភាពផ្លូវចិត្ត និងឱកាសសេដ្ឋកិច្ចពិតប្រាកដ ពីព្រោះខ្ញុំបានឃើញអ្វីដែលកើតឡើងនៅពេលដែលយើងមិនធ្វើ។ ហើយខ្ញុំនឹងគាំទ្រអាជីវកម្មខ្នាតតូចដែលរក្សាសហគមន៍របស់យើងឱ្យរស់រវើក។

បេក្ខជនរូបនេះមិនបានចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យទេ។



ឈ្មោះបេក្ខនារី៖ Alexis Rinck

ឈ្មោះយុទ្ធនាការ៖ Alexis for Seattle

គេហទំព័រយុទ្ធនាការ៖ www.alexisforseattle.com/

មុខតំណែងក្រុង៖ តំណែងក្រុមប្រឹក្សាក្រុង 8

លេខទូរសព្ទយុទ្ធនាការ៖ 206-705-9305

ខ្ញុំមានមោទនភាពចំពោះអ្វីដែលការិយាល័យរបស់ខ្ញុំសម្រេចបានក្នុងរយៈពេលដ៏ខ្លីនេះ៖

- Championing Prop 1A ដែលបានអនុម័តដោយបាន 63% នៃការបោះឆ្នោតនៅឆ្នាំនេះ ដើម្បីផ្តល់មូលនិធិដល់ការសាងសង់លំនៅដ្ឋានដែលមានតម្លៃសមរម្យតាមរយៈការគិតពន្ធលើអាជីវកម្មធំៗ។

- ការដឹកនាំការប្រយុទ្ធដើម្បីការពារទីក្រុងរបស់យើងពីការផ្លាស់ប្តូរគោលនយោបាយសហព័ន្ធដោយធ្វើជាប្រធានគណៈកម្មាធិការដែលខិតខំប្រឹងប្រែងដោយកោះប្រជុំអ្នកជំនាញ និងអ្នកដឹកនាំក្នុងតំបន់។

- ការជំរុញគោលនយោបាយពន្ធដារវឌ្ឍនភាព កាត់បន្ថយបន្ទុកលើអាជីវកម្មខ្នាតតូច ខណៈពេលដែលការពារលំនៅដ្ឋានដែលមានតម្លៃសមរម្យ ការទទួលបានអាហារ និងសេវាកម្មផ្សេងទៀតពីការកាត់បន្ថយ។

ក្នុងនាមជាអ្នកជួលផ្ទះ អ្នកធ្វើដំណើរតាមឡានក្រុង និងជាអតីតអ្នករត់តុ ខ្ញុំពិតជារំភើបណាស់ដែលបានឈរឈ្មោះបោះឆ្នោតឡើងវិញ ដើម្បីបន្តការងារនេះ។ ខ្ញុំមានមោទនភាពដែលមានការគាំទ្រពី MLK Labor, The Stranger, One America Votes, The Urbanist, Democratic Council, Seattle City Councilmember Dan Strauss, សមាជិកសភានៅគ្រប់មណ្ឌលនីតិបញ្ញត្តិ Seattle, សមាជិកក្រុមប្រឹក្សា King ខោនធី នៅ Seattle និងជាច្រើនទៀត។ ខ្ញុំសង្ឃឹមថានឹងទទួលបានការគាំទ្ររបស់អ្នកផងដែរ!

សូមផ្តល់ប័ណ្ណប្រជាធិបតេយ្យរបស់អ្នក ហើយចូលទៅកាន់ AlexisForSeattle.com ដើម្បីស្វែងយល់បន្ថែម។

*បេក្ខជនរូបនេះកំពុងចូលរួមក្នុងកម្មវិធីប័ណ្ណប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខនារី៖** Dionne Foster

**ឈ្មោះយុទ្ធនាការ៖** Dionne ដើម្បីទីក្រុង Seattle

**គេហទំព័រយុទ្ធនាការ៖** dionnefoster.com

**មុខតំណែងក្រុង៖** មុខតំណែងក្រុមប្រឹក្សាក្រុង Seattle លេខ 9

**លេខទូរសព្ទយុទ្ធនាការ៖** 206-651-5493

យើងសមនឹងទទួលបានផ្លូវដ៏មានសុវត្ថិភាព លំនៅឋានតម្លៃសមរម្យ និងមេដឹកនាំទីក្រុង Seattle ដែលការពារសិទ្ធិរបស់យើង និងគោរពសំឡេងរបស់យើង។

លោកស្រី Dionne Foster គឺជាអ្នកជំនាញខាងគោលនយោបាយ អ្នកដឹកនាំសហគមន៍ បុគ្គលិកសង្គមដែលបានទទួលការបណ្តុះបណ្តាល និងជាម្តាយដែលបានចំណាយពេលជាងមួយទសវត្សរ៍ដើម្បីធ្វើឱ្យសហគមន៍របស់យើងកាន់តែមានសុវត្ថិភាព និរន្តរភាព និងសមធម៌ជាងមុន។ នាងកំពុងឈរឈ្មោះក្នុងការបោះឆ្នោតយកមុខតំណែងក្រុមប្រឹក្សាក្រុងដើម្បីកសាងបន្ថែមពីលើកំណត់ត្រានៃភាពជាអ្នកដឹកនាំដ៏រឹងមាំរបស់នាង ដោយធ្វើឱ្យក្រុមប្រឹក្សាផ្តោតឡើងវិញ មកដោះស្រាយអាទិភាពរួមគ្នា និងតម្រូវការជាបន្ទាន់ មិនមែនលើរបៀបវារៈផ្ទាល់ខ្លួនទេ។

ក្នុងនាមជានាយកប្រតិបត្តិនៅសម្ព័ន្ធ WA Progress Alliance នាងបានជួយអនុម័ត និងការពារការវិនិយោគជាប្រវត្តិសាស្ត្រក្នុងការថែទាំកុមារ ការអប់រំដល់កុមារតូចៗ និងការកសាងសាលារៀនតាមរយៈភាពជាអ្នកដឹកនាំរបស់នាងក្នុងការប្រមូលយកពន្ធមូលធនទូទាំងរដ្ឋ ដោយធ្វើឱ្យប្រាកដថា អ្នកមានទ្រព្យសម្បត្តិបង់ចំណែករបស់ពួកគេឱ្យបានស្មើភាពគ្នា និងដោះស្រាយបញ្ហាតម្លៃឱ្យមានភាពសមស្រប និងតម្រូវការថវិកានានា។

ក្នុងនាមជាទីប្រឹក្សាគោលនយោបាយជាន់ខ្ពស់នៅទីក្រុង Seattle លោកស្រី Dionne បានគ្រប់គ្រងការចូលរួមរបស់អ្នកពាក់ព័ន្ធ ដើម្បីកែលម្អសុវត្ថិភាពសាធារណៈ បង្កើតឱកាសសម្រាប់យុវជន និងបំពេញតាមតម្រូវការសម្រាប់គោលដៅអាកាសធាតុ។ នៅមូលនិធិ Seattle Foundation នាងបានវិនិយោគនៅក្នុងអង្គភាព ដែលបង្កើតយុទ្ធសាស្រ្តលំនៅឋានថ្មី និងលើកកម្ពស់ភាពរឹងមាំខាងសេដ្ឋកិច្ច។

ជាមួយនឹងការគាំទ្ររបស់លោកអ្នក លោកស្រី Dionne នឹងរួមគ្នាជួយដឹកនាំទីក្រុង Seattle ដើម្បីដោះស្រាយបញ្ហាប្រឈមថ្នាក់ជាតិ និងជំរុញឱ្យមានវឌ្ឍនភាពក្នុងតំបន់ ដើម្បីជួយអ្នកគ្រប់គ្នាឱ្យមានសុខសុវត្ថិភាព ទទួលបានការស្វាគមន៍ និងការគាំទ្រនៅក្នុងទីក្រុងរបស់យើង។ លោកស្រី Dionne គឺជាបេក្ខភាពតែមួយគត់នៅក្នុងការឈរឈ្មោះបោះឆ្នោតនេះ ដែលត្រូវបានគាំទ្រដោយក្រុមប្រឹក្សាការងារ MLK។

*បេក្ខនារីនេះកំពុងចូលរួមក្នុងកម្មវិធីប័ណ្ណប្រជាធិបតេយ្យ។*



**ឈ្មោះបេក្ខជន៖** Sara Nelson

**ឈ្មោះយុទ្ធនាការ៖** Sara Nelson សម្រាប់ក្រុមប្រឹក្សាក្រុង

**គេហទំព័រយុទ្ធនាការ៖** SaraForCityCouncil.com

**មុខតំណែង៖** ក្រុមប្រឹក្សាក្រុងស៊ីថល តំណែងទី ៩ ទូទៅ

**លេខទូរសព្ទយុទ្ធនាការ៖** 206-821-6140

ខ្ញុំគឺ Sara Nelson ជាសមាជិកក្រុមប្រឹក្សាក្រុងរបស់អ្នក។

កាលពីបួនឆ្នាំមុន ទីក្រុង Seattle បានជាប់គាំង - ប្រឈមមុខនឹងឧក្រិដ្ឋកម្មកើនឡើង ការបោះជំរុំនៅក្នុងឧទ្យានរបស់យើង និងក្រុមប្រឹក្សាដែលហាក់ដូចជាចាប់អារម្មណ៍ក្នុងការធ្វើសេចក្តីថ្លែងការណ៍ជាជាងធ្វើឱ្យមានការរីកចម្រើន។ ខ្ញុំបានឈរឈ្មោះដើម្បីផ្លាស់ប្តូរវា។

ថ្ងៃនេះ ទីបំផុតយើងកំពុងផ្លាស់ប្តូរទិសដៅ។ ទីក្រុង Seattle កំពុងមន្ត្រីប៉ូលិសច្រើនជាងចំនួនដែលយើងបាត់បង់ ជាលើកដំបូងចាប់តាំងពីឆ្នាំ 2019។ យើងកំពុងប្រឈមមុខដោះស្រាយការរីករាលដាលនៃគ្រឿងញៀន fentanyl ដោយពង្រីកភាពជាដៃគូរបស់យើងជាមួយសេវាកម្ម Evergreen Treatment Services ដែលនាំមកជូននូវថ្នាំចល័ត និងការជំនួយរដោយផ្ទាល់ដល់មនុស្សដែលមានបញ្ហាប្រើប្រាស់គ្រឿងញៀននេះ។ ហើយនៅពេលដែលអាជីវកម្មក្នុងតំបន់ប្រឈមមុខនឹងការទម្លាយចូលលួចអីវ៉ាន់ យើងបានបង្កើតមូលនិធិជួសជុល Storefront Repair Fund ដើម្បីជួយពួកគេឱ្យដំណើរការឡើងវិញពីការចំណាយរបស់ពួកគេ។

មនុស្សគ្រប់រូបសមនឹងទទួលបានសិទ្ធិដូចគ្នាសម្រាប់ការសង្គ្រោះដូចដែលខ្ញុំបានទទួល។ នោះហើយជាមូលហេតុដែលខ្ញុំបានផ្តោតលើការផ្តល់ការព្យាបាលដោយឥតគិតថ្លៃតាមតម្រូវការ ខណៈពេលដែលធ្វើឱ្យការឆ្លើយតបគ្រាអាសន្ននៅទូទាំងទីក្រុងរបស់យើងកាន់តែប្រសើរឡើង។

ខ្ញុំជឿជាក់លើការផ្តល់ជូនលទ្ធផល មិនមែនការជជែកវែកញែកមិនចេះចប់នោះទេ។ មិនថា នោះគឺជាការជួយអាជីវកម្មខ្នាតតូចឱ្យរីកចម្រើន ឬការគាំទ្រស្ថាប័នតាមសហគមន៍ដែលធ្វើឱ្យទីក្រុងរបស់យើងមានភាពរស់រវើកនោះទេ។

បញ្ហាប្រឈមដែលយើងមានគឺស្មុគស្មាញ ប៉ុន្តែរួមគ្នា យើងអាចធ្វើឱ្យមានការរីកចម្រើនពិតប្រាកដ។ ខ្ញុំពិតជាមានកិត្តិយសក្នុងការទទួលបានការគាំទ្ររបស់អ្នកដើម្បីបន្តការងារនេះ។

*បេក្ខជនរូបនេះមិនបានចូលរួមក្នុងកម្មវិធីបណ្ណប្រជាធិបតេយ្យទេ។*